# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 461

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពផលិតផលម្ហូបអាហារ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/06/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 01/06/29 |

៣. ចំណាយគម្រោងសរុប $6,448,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងពាណិជ្ជកម្ម

| | |
|---|---|
| RESPONSIBLE UNIT | General Department of Consumer Protection, Competition and Fraud Repression (CCF) |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទានៈ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ជាទូទៅការអភិវឌ្ឍរចនាសម្ព័ន្ធគុណភាពមន្ទីរពិសោធន៍មានមុខងារផ្តល់សារៈសំខាន់ចាំបាច់ ខ្លាំងសម្រាប់ធានាដល់ការវាយតម្លៃអនុលោមភាពនៃប្រព័ន្ធត្រួតពិនិត្យ និងវិញ្ញាបនប័ត្រកម្មលើផលិតផលកសិ-ម្ហូបអាហារ របស់កម្ពុជា។ ការរួមចំណែកសំខាន់ៗ ដែលទទួលបានពីការអនុវត្តនៃគម្រោងមានៈ

- -ធានាសន្តិសុខស្បៀង និង សុវត្ថិភាពម្ហូបអាហារ ដើម្បីការពារសុខភាព និងសុខុមាលភាពប្រជាពលរដ្ឋគ្រប់រូបនិងធានាការអនុវត្តសមធម៌ក្នុងពាណិជ្ជកម្មម្ហូបអាហារ
- -ផ្តល់ទំនុកចិត្តនិងបង្កើនការគាំទ្រពីអតិថិជន លើវិស័យ សេវាកម្មវិភាគ និងធ្វើតេស្តលើផលិតផលកសិ-ម្ហូបអាហារសម្រាប់ការធ្វើអាជីវកម្មម្ហូបអាហារក្នុងស្រុក និងនាំចេញទៅកាន់ទីផ្សារសាកល
- -ជួយដល់ស្ថាប័នជាតិ ក្នុងការអនុវត្តច្បាប់ ប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាព
- -ជួយដល់វិស័យឯកជនតាមរយៈធ្វើឱ្យក្រុមហ៊ុនឱ្យកាន់តែមានភាពប្រកួតប្រជែង
- -ធានាបាននូវការលក់និងចែកចាយផលិតផលម្ហូបអាហារនៅលើទីផ្សារក្នុងស្រុក មានគុណភាព សុវត្ថិភាព និងអនាម័យ ដែលនឹងជំរុញផ្តល់ការគាំទ្រដល់ការប្រើប្រាស់ផលិតផលក្នុងស្រុក សំដៅកាត់បន្ថយការនាំចូលពីក្រៅប្រទេស ។

**១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា**

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

**ការកែលម្អបរិស្ថាននិយ័តកម្ម (វិធានការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ ការពង្រឹងបទដ្ឋានឧស្សាហកម្មនិងកម្មសិទ្ធិឧស្សាហកម្ម ការសម្រួលការបំពេញកាតព្វកិច្ចគយនិងអាករ និងការរៀបចំទីផ្សារពលកម្មនិងទំនាក់ទំនងវិជ្ជាជីវៈ)**

**១១. វិស័យ** (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

**កសិកម្ម និងការគ្រប់គ្រងដីធ្លី**

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

ផ្តល់ការពារសុខភាព និងសុខុមាលភាពអ្នកប្រើប្រាស់ពីផលប៉ះពាល់ដោយសារការប្រើប្រាស់ផលិតផលគ្មានសុវត្ថិភាព ក្លែងបន្លំគុណភាព បន្លំប្រភព និងជំរុញការនាំចេញផលិតផលរបស់កម្ពុជាទីកាន់ទីផ្សារក្នុងតំបន់និង អន្តរជាតិ ព្រមជាមួយនឹងការគាំទ្រដល់ប្រតិបត្តិ ករអាជីវកម្មម្ហូបអាហារក្នុងការផលិត កែច្នៃ វេចខ្ចប់ ចែកចាយនិងនាំចេញ-នាំចូលម្ហូបអាហារមានគុណភាព និងសុវត្ថិភាពសមស្របតាមគោលដៅប្រើប្រាស់។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កែច្នៃម្ហូបអាហារ ទាមទារនូវការតម្រូវចាំបាច់នូវហេដ្ឋារចនាសម្ព័ន្ធមន្ទីរពិសោធន៍ ដ៏រឹងមាំ ប្រកបដោយគុណភាព សម្រាប់ជួយគាំទ្រដោយផ្អែក លើមូលដ្ឋានវិទ្យាសាស្ត្រ ក្នុងការវិភាគម្ហូបអាហារឱ្យបានសមស្រប តាមលក្ខខណ្ឌស្តង់ដាគុណភាព និងសុវត្ថិភាពម្ហូបអាហារ ដើម្បីធានាបាននូវអាហារដែលមានសុខភាពល្អ អនាម័យ និងសុវត្ថិភាព ដល់អ្នកប្រើប្រាស់ និងសមស្រប ទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលបានកំណត់។ លើសពីនេះ តម្រូវការសេវាកម្មមន្ទីរពិសោធន៍ មានសារសំខាន់ចាំបាច់ដើម្បី ៖

(ក) វិភាគគុណភាពផលិតផលក្នុងស្រុក ដើម្បីធានាអនុលោមតាមស្តង់ដាជាតិ ក៏ដូចជាស្តង់ដាអន្តរជាតិសម្រាប់ការនាំចេញ និង

(ខ) វិភាគផលិតផលនាំចូលមកក្នុងប្រទេសដើម្បីធានាថាផលិតផលទាំងនោះមានអនុលោមភាពស្រប តាមស្តង់ដា សុវត្ថិភាព ជាអាទិ៍ កម្រិតនៃការចម្លងសារជាតុពុល សារជាតុបន្ថែម និងសំណល់ថ្នាំសម្លាប់សត្វល្អិតនៅក្នុងអាហារ ដែលចាំបចាំត្រូវតែមានការត្រួតពិនិត្យជាប្រចាំ។

ដូច្នេះតម្រូវការសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពិសោធន៍វិភាគអាហារគឺជាការចាំបាច់ ដើម្បីគាំទ្រដល់សកម្មភាពអនុវត្តច្បាប់ បទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារ និងជួយដល់ឧស្សាហកម្មកែច្នៃម្ហូបអាហារ ទាក់ទងនឹងការអនុវត្តតាមគោលការណ៍ គ្រប់គ្រងគុណភាព និងសុវត្ថិភាពម្ហូបអាហារ ដែលជាកម្មវិធីបង្ការទុកជាមុន មានដូចជា ការអនុវត្តកសិកម្មល្អ ការអនុវត្តការផលិតល្អ ការអនុវត្តអនាម័យល្អ និងប្រព័ន្ធវិភាគចំណុចត្រួតពិនិត្យក្នុងងារបង្ករគ្រោះថ្នាក់សំខាន់ៗ។ ដើម្បីសម្រេចបាននូវការគាំទ្រគម្រោងនេះ តម្រូវការជាតុចូលមួយចំនួនដែលត្រូវផ្តល់មាន៖

(១)ការបំពាក់ឧបករណ៍និងសំភារៈមន្ទីរពិសោធន៍ចាំបាច់សម្រាប់វិភាគគុណភាព និងសុវត្ថិភាពម្ហូបអាហារមានដូចជា មីក្រូជីវសាស្ត្រ សារជាតុចម្លងប្រភេទផ្សិតមីកូតុកស៊ីន សារជាតុចម្លងប្រភេទលោហៈធាតុធ្ងន់ សារជាតុបន្ថែម សំណល់ថ្នាំពុលកសិកម្ម សំណល់ថ្នាំព្យាបាលសត្វ និងសារជាតុផ្តល់អាហារូបត្ថម្ភ និងមីក្រូអាហារូបត្ថម្ភប្រភេទរ៉ែនិងវីតាមីន ។

(២) ការបណ្តុះបណ្តាលជំនាញលើការប្រើប្រាស់ និងថែទាំឧបករណ៍ពិសោធន៍ និង វិធីសាស្ត្រវិភាគ។

(៣) ការបណ្តុះបណ្តាលដល់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារពីគោលការណ៍ស្តីពីការអនុវត្តតាម ស្តង់ដាបច្ចេកទេស វិធានសុវត្ថិភាព អនាម័យម្ហូបអាហារ នីតិវិធីនិងបែបបទសម្រាប់ការនាំចេញនិងនាំចូល និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

(៤) ការប្រមូលនិងកសាងទិន្នន័យសម្រាប់រៀបចំនីតិវិធីត្រួតពិនិត្យម្ហូបអាហារផ្អែកលើហានិភ័យ។

(៥) ការកសាងនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងមន្ទីរពិសោធន៍តាមស្តង់ដា ISO 17025។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារត្រូវបានដាក់ឱ្យប្រើប្រាស់ខែមិថុនា ឆ្នាំ២០២២ ដែលក្នុងនោះកម្ពុជាត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍យោងនិងមន្ទីរពិសោធន៍ផ្លូវការដើម្បីធានាការធ្វើអធិការកិច្ចម្ហូបអាហារ
និងការគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារនៅតាមគ្រប់ខ្សែច្រវាក់ផលិតកម្មម្ហូបអាហារ ឱ្យបានសមស្របតាមការតម្រូវស្តង់ដា
និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីការពារសុខភាព
និងសុខុមាលភាពអ្នកប្រើប្រាស់ពីផលប៉ះពាល់ដោយសារការប្រើប្រាស់ផលិតផលគ្មានសុវត្ថិភាព ក្លែងបន្លំគុណភាព បន្លំប្រភព
និងជំរុញការនាំចេញផលិតផលរបស់កម្ពុជាទីកាន់ទីផ្សារក្នុងតំបន់និង អន្តរជាតិ ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកដែលទទួលបានផលប្រយោជន៍ផ្ទាល់ពីគម្រោង៖
- -ក្រសួងស្ថាប័នពាក់ព័ន្ធគុណភាព សុវត្ថិភាពម្ហូបអាហារដូចដែលអនុវត្តច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- -ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ អាចបង្កើនផលិតភាព និងជំរុញការនាំចេញផលិតផលម្ហូបអាហារកែច្នៃ និងកសិផលរបស់កម្ពុជាទៅកាន់ទីផ្សាក្នុងតំបន់និងពិភពលោក

អ្នកដែលទទួលបានផលប្រយោជន៍មិនផ្ទាល់ពីគម្រោង៖
- -ប្រជាជនគ្រប់រូបអាចទទួលបាន និងមានលទ្ធភាពមានស្បៀងប្រកបដោយសុវត្ថិភាព និងគុណភាព
ដើម្បីធានាបានជីវភាពរស់នៅសមស្របតាមចំណង់ចំណូលចិត្ត និងចូលរួមសកម្មក្នុងសង្គម ដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទានចាប់ផ្តើម** |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងមានគោលដៅចូលរួមចំណែកផងដែរក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការធានាបាននូវសុវត្ថិភាពស្បៀង
និងជំរុញការនាំចេញ ការបង្កើតទីផ្សារបោះដុំ និងចែកចាយផលិតផលកសិកម្មក្នុងស្រុក
ការរៀចំឱ្យមានកម្មវិធីត្រួតពិនិត្យនិងតាមដានលើអនុលោមភាពផលិតផលតាមស្តង់ដា ផ្នែកសុខភាពនិងអនាម័យ
និងជួយដល់ប្រជាពលរដ្ឋក្នុងការទិញ ការទទួល និងជ្រើសរើសម្ហូបអាហារមានគុណភាព សុវត្ថិភាព និងអនាម័យ និងសន្សំថវិកាពីការព្យាបាលជំងឺដែលបណ្តាលមកពីម្ហូបអាហារ។

១៩. ការប្រែប្រួល អាកាសធាតុ

| | |
|---|---|
| ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? | មាន |
| ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស | **ការបន្សាំ** |

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១៨. ជីវភាពរស់នៅ (ទូទៅ)** | 10 | **ទាក់ទងតិចតួច** |

២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | គ្មាន |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងមិនមានភាពប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រី ប៉ុន្តែនឹងជំរុញការកម្ពស់សមភាពយេនឌ័រ ក្នុងវិស័យកសិកម្ម និង វិស័យឧស្សាហកម្មកែច្នៃម្ហូបអាហារ និង ការជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈការបង្កើនគុណភាព និងផលិតភាពនៃផលិតផលម្ហូបអាហាររបស់កម្ពុជា។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

សកម្មភាពអនុវត្តគម្រោងអាចមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- -កង្វះខាតផ្នែកសេវាកម្មវិស្វកម្មក្នុងការថែទាំ ដើម្បីធានាភាពត្រឹមត្រូវរបស់ ឧបករណ៍វិភាគ

និងចរន្តអគ្គិសនីកាត់ផ្តាច់ដោយពេលខ្លះធ្វើឲ្យមានការលំបាកនិងប៉ះពាល់ដល់ដំណើរការរៀបចំការវិភាគ ក្នុងមន្ទីរពិសោធន៍

**២៣.** [illegible] មាននានា ដែល បណ្តាល ឲ្យ [illegible]

- -ការស្នើសុំការវិនិយោគដោយប្រើប្រាស់ថវិកាជាតិនៅមានកម្រិត ចាំបាច់ត្រូវមានការចូលរួមពីដៃគូអភិវឌ្ឍន៍

ក៏ដូចជាវិស័យឯកជនដែលមានបំណងវិនិយោគលើការផ្តល់សេវាវិភាគម្ហូបអាហារ

- -ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់គ្រប់គ្រាន់

ពាក់ព័ន្ធលក្ខខណ្ឌតម្រូវសម្រាប់ក្នុងការចុះបញ្ជីផលិតផលម្ហូបអាហារនាំចូលដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌធ្វើតេស្តលើប៉ារ៉ាម៉ែត្រចាំបាច់ ។

- -ការវិនិយោគមានរយៈពេលវែងដើម្បីអាចទទួលបានចំណូលជាតិសងត្រឡប់មកវិញ ដែលចាំបាច់ត្រូវមានការគាំទ្រពីដៃគូអភិវឌ្ឍន៍

សកម្មភាពអនុវត្តគម្រោងអាចមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- -កង្វះខាតផ្នែកសេវាកម្មវិស្វកម្មក្នុងការថែទាំ ដើម្បីធានាភាពត្រឹមត្រូវរបស់ ឧបករណ៍វិភាគ

និងចរន្តអគ្គិសនីកាត់ផ្តាច់ដោយពេលខ្លះធ្វើឲ្យមានការលំបាកនិងប៉ះពាល់ដល់ដំណើរការរៀបចំការវិភាគ ក្នុងមន្ទីរពិសោធន៍

- -ការស្នើសុំការវិនិយោគដោយប្រើប្រាស់ថវិកាជាតិនៅមានកម្រិត ចាំបាច់ត្រូវមានការចូលរួមពីដៃគូអភិវឌ្ឍន៍

ក៏ដូចជាវិស័យឯកជនដែលមានបំណងវិនិយោគលើការផ្តល់សេវាវិភាគម្ហូបអាហារ

- -ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់គ្រប់គ្រាន់

ពាក់ព័ន្ធលក្ខខណ្ឌតម្រូវសម្រាប់ក្នុងការចុះបញ្ជីផលិតផលម្ហូបអាហារនាំចូលដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌធ្វើតេស្តលើប៉ារ៉ាម៉ែត្រចាំបាច់ ។

- -ការវិនិយោគមានរយៈពេលវែងដើម្បីអាចទទួលបានចំណូលជាតិសងត្រឡប់មកវិញ ដែលចាំបាច់ត្រូវមានការគាំទ្រពីដៃគូអភិវឌ្ឍន៍

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

- -ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- -អង្គការសហប្រជាជាតិសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO)
- -អង្គការស្បៀងនិងកសិកម្ម សហប្រជាជាតិ (FAO)
- -អង្គការសុខភាពពិភពលោក (WHO)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 540.0 | 540.0 | 540.0 | 1,620.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 240.0 | 240.0 | 240.0 | 720.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 260.0 | 260.0 | 260.0 | 780.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 40.0 | 40.0 | 40.0 | 120.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 1,310.0 | 1,765.0 | 1,753.0 | 4,828.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 40.0 | 40.0 | 30.0 | 110.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 120.0 | 120.0 | 120.0 | 360.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 1,100.0 | 1,555.0 | 1,553.0 | 4,208.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 30.0 | 30.0 | 30.0 | 90.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,850.0 | 2,305.0 | 2,293.0 | 6,448.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 300.0 | 350.0 | 400.0 | 1,050.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 1,400.0 | 1,400.0 | 1,400.0 | 4,200.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 1,400.0 | 1,400.0 | 1,400.0 | 4,200.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Other | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 1,400.0 | 1,400.0 | 1,400.0 | 4,200.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 450.0 | 905.0 | 893.0 | 2,248.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: